## រឿងទី៤៖ ម៉ូសេ១ (ទារកតូចម៉ូសេ)

**ខគម្ពីរ៖ និក្ខមនំ ២៖១០**

ព្រះនាងដាក់ឈ្មោះថា «ម៉ូសេ» ដោយមានសេចក្ដីន័យថា៖ «ខ្ញុំបានស្រង់កូននេះចេញពីទឹកមក»។

ជនជាតិអ៊ីស្រាអែល បានរស់នៅក្នុងស្រុកអេស៊ីបអស់រយៈពេលជាងបួនរយឆ្នាំ។
ដោយព្រះគុណព្រះជាម្ចាស់ ជនជាតិអ៊ីស្រាអែលបានង្កើតកូនជាច្រើនពេញស្រុកអេស៊ីប។
ប៉ុន្តែស្តេចផារ៉ោនមានការព្រួយបារម្ភជាខ្លាំងព្រោះកូនចៅជនជាតិអ៊ីស្រាអែលកាន់តែច្រើនឡើងបែបនេះ។
ដូច្នេះ ស្តេចផារ៉ោន បានធ្វើទុក្ខទោសដល់ជនជាតិអ៊ីស្រាអែលជាខ្លាំងដោយឱ្យពួកគេធ្វើជាទាសករ វាយធ្វើបាប យ៉ាងព្រៃផ្សៃ។
ប៉ុន្តែ ជនជាតិអេស៊ីបកាន់តែធ្វើបាបជនជាតិអ៊ីស្រាអែល ជនជាតិអ៊ីស្រាអែលកាន់តែមានចំនួនច្រើនទៅៗ ដោយព្រះគុណព្រះជាម្ចាស់។
មានថ្ងៃមួយ ស្តេចផារ៉ោន បានកោះហៅពួកឆ្មបទាំងអស់ឱ្យមកជួប។ ឆ្មបគឺជាអ្នកជួយសម្រាលកូន។
ស្តេចផារ៉ោនបានប្រាប់ទៅពួកឆ្មបដែលជួយសម្រាលកូនឱ្យពួកស្រីៗសាសន៍អ៊ីស្រាអែលថាបើគេសម្រាលបានកូនស្រីនោះចូរទុកឱ្យនៅរស់ចុះ
ប៉ុន្តែបើសម្រាលបានកូនប្រុសវិញ ត្រូវបោះចូលទៅទន្លេនីលសម្លាប់ចោលទៅ។
ប៉ុន្តែពួកឆ្មបទាំងនោះ ជាអ្នកកោតខ្លាចព្រះជាម្ចាស់ ក៏បានជួយកូនប្រុសៗឱ្យនៅរស់វិញ។
ព្រះជាម្ចាស់បានប្រទានពរដល់ពួកឆ្មបទាំងនោះ។



ព្រះជាម្ចាស់បានស្តាប់ការអធិស្ឋាន និងការទទូចអង្វររបស់ពួករាស្ត្រអ៊ីស្រាអែល ទ្រង់ក៏បានជួយសង្គ្រោះពួកគេ។
មានថ្ងៃមួយ មានស្ត្រីសាសន៍អ៊ីស្រាអែលម្នាក់រស់នៅក្នុងស្រុកអេស៊ីបបានបង្កើតកូនប្រុសម្នាក់។
ដោយកូនប្រុសដែលទើបនិងកើតនោះមានរូបស្រស់ល្អនិងគួរឱ្យស្រឡាញ់ពេក ទើបស្ត្រីនោះមិនដាច់ចិត្តបោះកូន ទៅក្នុងទន្លេនីលទេ។
ដូច្នេះ ក៏សម្រេចលាក់ទុកចិញ្ចឹមបានបីខែ។
ប៉ុន្តែ ដោយសម្លេងយំរបស់កូនតូចនោះតែខ្លាំងឡើងៗដូច្នេះ ធ្វើឱ្យម្តាយមិនអាចចិញ្ចឹមកូននោះបានទៀតទេ។
ម្តាយរបស់កូនតូចនោះ បានអធិស្ឋានទាំងទួញយំទូលទៅព្រះជាម្ចាស់។
ទីបំផុត ស្ត្រីក៏យកកន្ត្រកធ្វើពីដើមបបុស មកពរជ័រលាបម្រ័ក្សណ៍ដើម្បីកុំឱ្យលេច រួចដាក់កូនតូចក្នុងកន្ត្រកនោះ។
ហើយបន្ទាប់មក នាងក៏យកកន្ត្រកដែលបានដាក់កូននោះទៅបណ្តែតនៅក្នុងទន្លេនីល។



ម៉ារាមជាបងស្រីរបស់កូនតូចនោះក៏លាក់ខ្លួនតាមគុម្ពព្រៃងតាមមើលប្អូនពីចម្ងាយរហូត។
កន្ត្រកដែលមានកូនតូចនៅក្នុងនោះបានអណ្តែតរសាត់តាមទឹក រហូតទៅដល់កន្លែងបុត្រីស្តេចផារ៉ោនស្រង់ទឹក។
ព្រះនាង បានឃើញកន្ត្រកដែលអណ្តែតមកជាប់នឹងគុម្ពព្រៃង។ ភ្លាមនោះ ម៉ារាមដែលកំពុងលាក់ខ្លួនក៏រត់មករកព្រះនាង។
ម៉ារាមក៏បានសួរទៅព្រះនាងថាចង់រកមនុស្សមកមើលថែកូនតូចនោះដែរទេ។
ព្រះនាងក៏ឆ្លើយទៅនាងថាកំពុងស្វែងរកអ្នកមើលថែកូនតូចនោះ។
ម៉ារាម សប្បាយចិត្តជាខ្លាំងក៏ប្រញាប់រត់ទៅផ្ទះវិញយ៉ាងលឿន។
នាងបាននិយាយប្រាប់ទៅម្តាយនាង។ ម្តាយកូនតូចនោះក៏ប្រញាប់រត់ទៅជួបព្រះនាង។
ព្រះជាម្ចាស់បានឱ្យកូនតូចនោះរស់នៅជាមួយម្តាយរហូតដល់ធំពេញវ័យ។
ព្រះនាងបានដាក់ឈ្មោះឱ្យកូនតូចនោះថា«ម៉ូសេ»។ ម៉ូសេ គឺមានន័យថា ស្រង់ចេញពីទឹក។ ពីមួយថ្ងៃទៅមួយថ្ងៃ ម៉ូសេកាន់តែធំទៅៗ។
ម្តាយបង្កើតម៉ូសេបានអប់រំប្រៀនប្រដៅម៉ូសេឱ្យមានជំនឿបម្រើព្រះជាម្ចាស់។
ម៉ូសេបានក្លាយជាបុត្រារបស់ព្រះនាង ហើយទទួលបានការអប់រំជាច្រើននៅក្នុងវាំងជាមួយនឹងបុត្រាៗផ្សេងទៀត។
ជាច្រើនឆ្នាំកន្លងទៅ ព្រះជាម្ចាស់បានធ្វើឱ្យម៉ូសេក្លាយជាអ្នកដឹកនាំដ៏អស្ចារ្យដឹកនាំជនជាតិអ៊ីស្រាអែល។
ម៉ូសេបានធ្វើតាមព្រះបន្ទូលព្រះជាម្ចាស់ ដឹកនាំជនជាតិអ៊ីស្រាអែលដែលរងទុក្ខក្នុងស្រុកអេស៊ីប ឱ្យត្រឡប់ទៅ ស្រុកកំណើតវិញ។
ពេលនេះ ជនជាតិអ៊ីស្រាអែលទាំងអស់ថ្វាយបង្គំព្រះជាម្ចាស់យ៉ាងខ្ជាប់ខ្ជួន និងបានក្លាយជារាស្ត្រដ៏មានសេរីភាព របស់ព្រះជាម្ចាស់ ។





**សកម្មភាពទី១** សូមឆ្លើយសំណួរខាងក្រោម។

a. តើស្តេចផារ៉ោនបានបង្គាប់ឱ្យពួកឆ្មបធ្វើអ្វី?

------------------------------------------------------------------------

b. តើពួកឆ្មបកោតខ្លាចនរណា ហើយតើពួកគេបានធ្វើអ្វីខ្លះចំពោះទារកប្រុសៗ?

------------------------------------------------------------------------

c. តើបុត្រីរបស់ស្តេចផារ៉ោនបានដាក់ឈ្មោះដល់ទារក ដែលព្រះនាងបានរកឃើញក្នុងកន្ត្រកមួយនាទន្លេនីល ថាដូចម្តេច?

------------------------------------------------------------------------

d.សូមអាន និក្ខមនំ ២៖៧-១០ រួចឆ្លើយសំណួរ។ តើអ្នកណាជាអ្នកចិញ្ចឹមម៉ូសេ ហើយតើនាងធ្វើបែបណាពេលដែលម៉ូសេធំឡើង?

------------------------------------------------------------------------

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (និក្ខមនំ ២៖១០)

ព្រះនាងដាក់ឈ្មោះថា «ម៉ូសេ» ដោយមានសវនីយ៍ថា៖ «ខ្ញុំបានស្រង់កូននេះចេញពីទឹកមក»។



**សកម្មភាពទី២** តើឈ្មោះលោកម៉ូសេមានន័យដូចម្ដេច? សូមដោះស្រាយលំហាត់ខាងក្រោម ព្រមទាំងប្រាប់ពីអត្ថន័យនៃឈ្មោះលោកម៉ូសេ។

| ដាក់ | សវនីយ៍ | ថា | សេ» | ឈ្មោះ | មាន | «ម៉ូ | ព្រះ | ដោយ | នាង | ៖ |
|---|---|---|---|---|---|---|---|---|---|---|
| ☞ | ↓ | ¥ | ◀ | ☎ | ☜ | ← | ® | ◐ | ★ | € |

| ស្រង់ | ។ | នេះ | ពី | កូន | មក» | ចេញ | «ខ្ញុំ | ទឹក | បាន |
|---|---|---|---|---|---|---|---|---|---|
| ◎ | X | # | ♠ | ♬ | ≠ | & | ▣ | ♧ | ◇ |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ® | ★ | ☞ | ☎ | ¥ | ← | ◀ | ◐ | ☜ | ↓ | ¥ | € | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ▣ | ◇ | ◎ | ♬ | # | & | ♠ | ♧ | ≠ | X | |

| | | | | | |
|---|---|---|---|---|---|
| និក្ខ | មនំ | | ២ | ៖ | ១០ |



